Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

## (3) My Father and Love



*SAOKHON Sireyvath*

Talking about Cambodia reminds us of the famous Angkor Temple, which draws many people to visit it at least once in their life time. But we also remember the dark age of the Pol Pot regime when millions of Cambodian lives were lost. There is no exact answer to the questions of what happened to all the people then.

I also am one of those who endured that horrible time. On April 17, 1975 all who lived in the city were forced by black-shirted solders to leave for the various provinces of Cambodia. My family was among them. Along the way were crowds of people. My father and family were unsure of where to go; we just followed the crowds. At that time I was only six years old. My father said, "Come, I'll carry you," and he carried me and later put me on his back. When I was on his back, I felt very happy and warm. Nothing could compare with this peace. While we are walking along the way I frequently asked my father, "Father, father, are you weary?" He answered, "No." I asked him many times about what I was seeing but didn't understand. Often time we laughed together and were very happy.

This reminds me of the love between a father and his son. God is not different—he loves us as his children, he protects us, he carries us away from the trouble that arises from sin. His love means that he never complains, but continually protects us in all circumstances because he loves us as his children. The Bible says, "... in the wilderness ... you saw how Yahweh your God carried you, as a father carries his son, all the way you went until you reached this place" (Deut 1:31).

- Whenever son face a problem, the father always protects him.
- Protection is love.
- In his love God sacrifices everything to protect and care for us.

## Conclusion

Perhaps the preceding has prompted *you* to write an article for *Honeycomb*. If so, we offer, with tongue in cheek, the following advice to our English authors:

### Advice to Our Contributors
### "How to Write Good"

1. Avoid run on sentences they are hard to read.
2. About sentence fragments.
3. It behooves us to avoid archaisms.
4. Also avoid awkward or affected alliteration.
5. Don't use no double negatives.
6. If I've told you once I've told you a million times: don't exaggerate.
7. Avoid commas, that aren't necessary.
8. Verbs has to agree with their subjects.
9. Likewise, pronouns have to agree with its referents.
10. Use of the passive voice should be avoided.
11. Never use a long word when a miniscule one will do.
12. Don't verb nouns.
13. Kill all exclamation marks!!!!!!
14. When dangling, don't use participles.
15. Who needs rhetorical questions?
16. Never, under any circumstances, use repetitive, repetitious redundancies.
17. Proofread carefully to sure you didn't any words out.
18. Eschew obfuscation, and employ the vernacular.
19. Prepositions are not words to end sentences with.
20. Avoid ampersands & abbrevs., etc.
21. Parenthetical remarks (however relevant) are unnecessary.
22. Remember to never split an infinitive.
23. Contractions aren't necessary.

24. Foreign words and phrases are not à propos.
25. One should never generalize.
26. Eliminate quotations. As Ralph Waldo Emerson once said, "I hate quotations. Tell me what you know."
27. Be more or less specific.
28. One-word sentences? Eliminate.
29. Even if a mixed metaphor sings, it should be derailed.
30. Beware of irregular verbs that have crope into our language.
31. Last but not least, avoid clichés like the plague (they're old hat).

សំណុំធីកឃ្មុំ ៥/១ (តុលា ២០០៤)៖ ២៧-៤៦

# អ្នកនិពន្ធសំរាប់កម្ពុជា

## សេចក្តីផ្តើម

"ការអានធ្វើឲ្យមនុស្សពេញលក្ខណៈផ្នែកចំណេះដឹងការចូលរួម នៅក្នុងសន្និបាតធ្វើឲ្យមនុស្សប្រុងប្រៀបខ្លួនដើម្បីបំពើការងារ ចំណែកឯការនិពន្ធធ្វើឲ្យមនុស្សដឹងច្បាស់ពីអំណោយទានរបស់ខ្លួន" ។ ហេតុដូច្នេះហើយបានជាលោក ហ្វ្រង់ស៊ីស បេកខនសរសើរយ៉ាងច្បាស់ចំពោះលក្ខណៈពិសេសនៃការនិពន្ធ។

មែនហើយគាត់និយាយនោះពិតជាត្រឹមត្រូវមែន ។ ការសរសេរហើយសរសេរទៀតផ្តល់ឱកាសឲ្យអ្នកនិពន្ធបានសំរួចពាក្យសំដីរបស់ខ្លួនរហូតដល់កំរិតមួយដែលខ្លួនចង់និយាយឲ្យគេបានដឹង ។នេះគឺជាការសប្បាយរីករាយ និង ចំណុចខ្លាំងនៃការប្រើស្លាបប៉ាកា ។ ពាក្យសំដីដែលនិយាយផ្ទាល់មាត់អាចបំពេញនូវសេចក្តីត្រូវការក្នុងមួយគ្រាបានមែន តែសិល្បៈនៃការនិពន្ធជាពាក្យស្លោក តែងសេចក្តី ឬ ការចងក្រងជាប្រជុំរឿងព្រេងជាដើមអាចឆិតជ្រុងផ្នែកអក្សរសិល្ប៍ឲ្យក្លាយជាគ្រាប់ពេជ្រដែលមានរស្មីភ្លឺផ្លេក ។ ពាក្យសំដីរបស់អ្នកល្បីៗនៅលើសាកលលោកជាច្រើនកើតចេញមកពីការខិតខំសិក្សាស្រាវជ្រាវយ៉ាងលំបាកពីអក្សរសិល្ប៍មុនពេលដែលអាចនិយាយចេញមក។ ការនិយាយវែងដែលមិនបានព្រៀងទុកនោះតែងតែវង្វេងចូលក្នុងពាក្យពេចន៍ឥតបានការ និងមិនចាំបាច់ត្រូវនិយាយ ។ ការកែសម្រួលអត្ថបទជួយកាត់សំអាតពាក្យពេចន៍ដែលមិនសម និងកាត់តម្រឹមពាក្យដែលនិយាយច្រំដែល ។ ពិតប្រាកដណាស់ ការសរសេរធ្វើឲ្យមនុស្សក្លាយជាមានលក្ខណៈសម្បត្តិពិតប្រាកដបាន ។ លោក អាធីហាន់ត៍ នៅពេលថ្មីៗបានលើកឡើងជាយោបល់

សង្កត់ធ្ងន់ទៅលើភាពជាក់លាក់នៃការសរសេរប្រៀបទៅនឹងការប្រាស្រ័យទាក់ទងដោយប្រើភ្នែកគឺវាសមនិងជំនឿរបស់គ្រីស្ទបរិស័ទ [៩]។

សំណោរទំនងជាឋិតថេរនៅយូរអង្វែងជាងគេ ។ ពាក្យសំដីរបស់អ្នកពូកែនិយាយអាចដក់ក្នុងត្រចៀកអ្នកស្តាប់ប្រហែលជាត្រឹមមួយខែប៉ុន្តែឯសំណេរវិញអាចជួយជាគំនិតដល់មនុស្សរាប់ជំនាន់ឯណោះ ។ សៀវភៅអត្ថបទ សំបុត្រគេអាចទាញយកចេញពីលើធ្នើមកអានហើយសញ្ជឹងគិតបាន ។ ពិចារណាឲ្យបានយល់ស៊ីជម្រៅ ពាក្យសរសេរអាចចាក់ឫសជ្រៅនៅក្នុងចិត្ត និង គំនិតរបស់មនុស្ស ។ វាអាចឈរជាស្មរបន្ទាល់រហូតដល់រាប់ទសវត្សរ៍ ។ អេបិលមិនមែនគ្រាន់តែជាម្នាក់ដែលនៅកំពុង" និយាយដាស់តឿនដល់មនុស្សផងទាំងពួងប៉ុណ្ណោះទេ ទោះបីជាគាត់បានស្លាប់បាត់សូន្យទៅហើយនោះ" ។ លោក ប៉ូល អេសាយ និង យ៉ូហានក៏ដូចគ្នាដែរគឺសំណេររបស់អ្នកទាំងនោះ ផ្តល់ជីវជាតិដល់ព្រលឹងមនុស្សរាប់សតវត្សរ៍មកហើយបន្ទាប់ពីអ្នកទាំងនោះ បានបន្តមកឲ្យមនុស្សជំនាន់ក្រោយៗមកទៀត។

ការសរសេរជាធម្មតាមានការបែងចែកយ៉ាងច្រើនសម្បើម។ ការបោះពុម្ពផ្សាយពីខិត្តប័ណ្ណ និង សេចក្តីអធិប្បាយរបស់បណ្ឌិតលូធើរ គឺមានសន្ទុះលឿនខ្លាំងក្លា និង ចាក់ឫសយ៉ាងជ្រៅនៅក្នុងការកែទម្រង់របស់គាត់ គឺផ្ទុយគ្នាស្រឡះពីការស្លាប់របស់លោកហាស់ និងក្រុមអ្នកគាំទ្រដល់គាត់ ។ សម្ភារៈដែលចេញពីការសរសេរគឺត្រូវចំណាយទុនតិច ប្រើបច្ចេកវិជ្ជាទាប តែជាមធ្យោបាយបង្វែរគំនិតដល់មនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់ណាស់ ។

[9] Arthur W. Hunt III, *The Vanishing Word: The Veneration of Visual Imagery in the Postmodern World*, Focal Point series, gen. ed. Gene Edward Veith, Jr. (Wheaton, Illinois: Crossway, 2003).

តែគួរឲ្យសោកស្តាយណាស់ដែលខិត្តប័ណ្ណផ្នែកអក្សរសិល្ប៍ខ្មែរ និង អ្នកនិពន្ធដែលបានផលិតអក្សរសិល្ប៍ទាំងនោះបានទទួលនូវការរងឈឺចាប់នៅក្នុង ចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩ ។ ការធ្លាក់ចុះនៅពេលនោះបណ្តាលឲ្យមានសន្ទុះលឿនយ៉ាងខ្លាំងនៅពេលសព្វថ្ងៃនេះ ។ ជនជាតិខ្មែរដែលជាជនសាមញ្ញមិនមែនជាអ្នកនិពន្ធ ឬ ក៏មិនមែនជាអ្នកចេះអានអក្សរជ្រៅជ្រះប៉ុន្មានដែរ (តែសប្បាយចិត្ត និង ករណីលើកលែងទាំងឡាយនោះ)។ ការនោះហើយដែលមានការផ្លាស់ប្រែ។ ចំណែកឯក្រុមជំនុំវិញនោះគឺត្រូវតែមានការផ្លាស់ប្រែ បើក្រុមជំនុំត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងការបង្រៀនអ្វីៗទាំងអស់ដែលព្រះអម្ចាស់បានត្រាស់បង្គាប់មកនោះ [២]។

ដើម្បីលើកស្ទួយជួយថែពន្លកថ្មីនៃអ្នកនិពន្ធគ្រីស្តបរិស័ទខ្មែរ គម្រោងកម្មវិធីហ្វីកហ្វីនធីម៉ូថេ នៅក្នុងពេលថ្មីៗនេះបានរៀបចំសិក្ខាសាលាពីរ។ សិក្ខាសាលាទីមួយនោះបានបង្រៀនដោយអ្នកនិពន្ធខ្មែរដែលធ្លាប់សម្រេចបាននូវការនិពន្ធផ្សេងៗគឺលោក បាណាបាស គង់ ផនឆុន អ៊ួន សិលា និង លោក សុខ ញ៉ិបអារុណ ។ ពីរអាទិត្យក្រោយមក យើងបានជ្រើសរើសមនុស្សមួយក្រុមដែលបានចូលរៀននូវវគ្គសិក្ខាសាលាទី ១ នោះ ឲ្យចូលរៀនបន្ត ៤ ថ្ងៃថែម ទៀតជាមួយលោក វ៉ែម៉ានវីស៍ ដែលអញ្ជើញមកពីក្រុមអ្នកបោះពុម្ពនៃរោងពុម្ពធីនឌែល ។ នៅពេលចុងបញ្ចប់សិក្ខាកាមតម្រូវឲ្យសរសេរជារឿងប្រៀបប្រដូចខ្លីៗ ។

នៅខាងក្រោមនេះគឺជាអ្វីបានឆ្លុះបញ្ចាំងឲ្យឃើញចេញពីសិក្ខាសាលាទីពីរ គឺជាសិក្ខាសាលាអ្នកនិពន្ធដែលបានបង្រៀនដោយលោកវីស៍ នោះបន្ទាប់មកសំណេររបស់សិក្ខាកាមបីរូប យើងបានជ្រើសរើសយក មកបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិប័ត្រសំណុំទឹកឃ្មុំ។ យើងសង្ឃឹមថាអ្នកដទៃនឹងចាប់យកនិមិត្តក្នុង

---

[២] ម៉ាថាយ ២៨:២០

ការហ្វឹកហ្វឺនដល់អ្នកនិពន្ធគ្រីស្គបរិស័ទខ្មែរ ជំនាន់ថ្មីនេះដើម្បីជួយឲ្យក្រុមជំនុំរៀបចំស្ពាលព្រោះព្រះបន្ទូលដែលដុះត្រង់ឆ្ពោះទៅរកទិសដៅជាប់នៅស្ថិតស្ថេរ និងមានអ្នកអានបានច្រើនទូលំទូលាយ ។

បណ្ណាធិការ

# ការសញ្ជឹងគិតពីសិក្ខាសាលា



*លោក វ៉ៃម៉ាន វីស៍*

រយៈពេលពេល ៤ថ្ងៃ មិនមែនយូរប៉ុន្មានទេដើម្បីចំណាយពេលនោះជាមួយបុរស និងស្ត្រី ទាំង១៥ នាក់ ដែលជាមនុស្សមានទឹកចិត្តគិតចង់ជួយអភិវឌ្ឍន៍ផ្នែកអក្សរសិល្ប៍ដើម្បីជួយដល់ក្រុមជំនុំនៅក្នុងប្រទេសកម្ពុជានោះ ។ ប៉ុន្តែរយៈពេលបួនថ្ងៃគឺនៅថ្ងៃទី ១-៤ ខែកញ្ញា ២០០៣ នោះបានបង្ហាញឲ្យខ្ញុំឃើញថាបំណងចិត្ត និង ការប្តេជ្ញាចិត្តដែលចាំបាច់បំផុត ខ្ញុំត្រូវផ្តល់វិភាគទានដ៏សំខាន់នោះគឺធ្វើឲ្យខ្ញុំមើលឃើញយ៉ាងច្បាស់ក្រឡេតក្នុងការប្រមូលផ្តុំគ្នានេះ ។

បំណងឆន្ទៈរបស់ខ្ញុំក្នុងការធ្វើដំណើរមកកាន់ប្រទេសកម្ពុជាក្នុងនាមជាអ្នកនិពន្ធ និង បណ្ណាធិការដែលមានបទពិសោធន៍ផ្នែកបោះពុម្ពសៀវភៅ និងទស្សនាវដ្តីនោះ គឺខ្ញុំមានការសន្និដ្ឋានបួនប្រាំយ៉ាងដែលខ្ញុំ មាននៅក្នុងគំនិត ។

ទីមួយខ្ញុំសន្និដ្ឋានថាគ្រប់ទាំងសំណោរទាំងឡាយមិនថាឡើយជាភាសាអ្វីឡើយគឺមានរចនាសម្ព័ន្ធគ្រប់គ្រាន់ល្មមតាមបែបដែលអាចធ្វើការបាន និង ដោយសារមានរចនាសម្ព័ន្ធបែបនោះឡើយដែលអាចបង្រៀនបានតាមរយៈនៃការបកប្រែ និង ការបកប្រែផ្ទាល់មាត់ផងនោះ ។ ខ្ញុំពិតជាមិនដឹងថា វាពិតជាត្រឹមត្រូវមែនឬអត់ទេ តែបទពិសោធន៍ក្នុងមួយអាទិត្យនេះបាននាំមកនូវគំនិតស៊ីជម្រៅថ្មីៗខ្លះចូល ទៅក្នុងលក្ខណៈរបស់បទគម្ពីរគឺតាមបែបអក្សរសាស្ត្រ និង ភាសាផ្ទាល់របស់បទគម្ពីរនោះ ។

ជំនឿគ្រីស្ទបរិស័ទបែបដំណឹងល្អពឹងផ្អែកទៅលើជំនឿដែលថា ភាសាដែលគេបានសរសេរនៅក្នុងព្រះគម្ពីរដើមគឺជាភាសាហេព្រើរ អារ៉ាមិក និងភាសាក្រេក ដែលព្រះជាម្ចាស់ទទួលស្គាល់ ។ ព្រះជាម្ចាស់ដែលបានធ្វើឲ្យមានផលវិបាកក្នុងការបំភាន់ភាសានៅក្នុងពេលបំផ្លាញប៉ម បាបែល ព្រះអង្គបានមានផែនការថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលត្រូវនាំមកឲ្យមនុស្សជាតិទាំងអស់នោះគឺត្រូវមកតាមរយៈបីភាសានេះ គឺល្មមគ្រប់គ្រាន់ក្នុងការបង្ហាញពីសេចក្ដីពិតដ៏ពិសិដ្ឋនោះបាន ។ តាំងពីនោះមកការខំប្រឹងប្រែងបកប្រែព្រះគម្ពីរបានខំស្វែងរកអ្នកប្រាជ្ញ និង អ្នកមានជំនាញផ្នែកភាសាដ៏ពិសិដ្ឋនេះឲ្យទៅជាភាសាទាំងឡាយដែល " មនុស្សគ្រប់កុលសម្ព័ន្ធ គ្រប់ភាសា និង គ្រប់ប្រជាជាតិអាចយល់បាន"[១]។

សូម្បីតែសៀវភៅពន្យល់ពីបទគម្ពីរសង្ខេបភាគច្រើនក៏បង្ហាញឲ្យឃើញពីប្រភេទនៃអក្សរសិល្ប៍មានដូចជាការអធិប្បាយបែបពង្រីកអត្ថន័យ បែបសន្ទនានិងបែបរៀបតាមលំដាប់នៃការប្រើភាសាប្រៀបធៀបបែបអត្ថបដិរូប និង បែបខិត្តប័ណ្ណខ្លីៗ ។ ការបកប្រែដែលត្រូវចាំៗនៃប្រភេទនៃអក្សរសាស្ត្រ

---

១ *វិវរណៈ ៥:៩*

ទាំងនេះក៏អាចបង្ហាញថាសូម្បីតែភាពស្រពិចស្រពិលពិបាកយកនៃទម្រង់បែបបទទាំងនោះក៏នៅតែអាចទៅរួចព្រោះតែនារខំប្រឹងប្រែងនៃការបកប្រែ ។

ខ្ញុំបានមកឃើញនូវរបៀបថ្មីមួយ ដែលនៅក្នុងប្រទេសកម្ពុជារចនាសម្ព័ន្ធនៃផ្នែកអក្សរសិល្ប៍ទាំងនេះគឺអាចគ្រប់គ្រងបានក្នុងការប្រែព្រះគម្ពីរ។ ដូច្នេះទំនងជាអត់បញ្ហាអ្វីទេ ដែលខ្ញុំអាចសន្និដ្ឋានថារបៀបប្រើអក្សរសិល្ប៍ដ៏សាមញ្ញខ្លះៗគឺពិតមិនខុសគ្នាទៅនឹងប្រទេសដទៃប៉ុន្មានទេ ។ ការសរសេរមានការវិវឌ្ឍន៍ទៅមុខនៅក្នុងកន្លែងខ្លះនៃពិភពលោកយើងនេះដើម្បីប្រាស្រ័យទាក់ទងដល់សង្គមមនុស្សដែល ជឿនលឿនដែលការផ្តោតយកចិត្តទុកដាក់នោះកាន់តែថយចុះ ។ គ្មានហេតុផលអ្វីដែលត្រូវមិនជឿថាសំណេរបែបដូចគ្នានេះដែរ នឹងត្រូវការជាចាំបាច់ក្នុងការឆ្លើយតប ទៅនឹងការចំរើនលូតលាស់យ៉ាងឆាប់រហ័សផ្នែកទំនៀមទំលាប់នៅក្នុងប្រទេសកម្ពុជា ។

មនុស្សទាំងអស់នៅពេលដែលបានចូលរួមសិក្ខាសាលាជាមួយគ្នាប្រហែលជាបានយល់ស្របតាមខ្ញុំដែរ ខ្ញុំជឿជាក់ថាវាមិនមែនជាការងាយស្រួលក្នុងការផ្តល់ឲ្យក្រុមជំនុំ និង អ្នកដឹកនាំក្រុមជំនុំនៅក្នុងប្រទេសខ្មែរនូវសម្បត្តិដ៏ពិសេសនៃខិត្តប័ណ្ណផ្នែកអក្សរសិល្ប៍មានលក្ខណៈជាគ្រីស្ទបរិស័ទមានដូចជា សៀវភៅពន្យល់ពីរបៀបបកស្រាយព្រះគម្ពីរ មេរៀនដែលផ្តល់នូវការស្រាយបំភ្លឺបទគម្ពីរសម្ភារៈសំរាប់អប់រំ និង សំរាប់ផ្សាយដំណឹងល្អ ដើម្បីបំពេញនូវសេចក្តីត្រូវការនៃការលូតលាស់របស់ក្រុមជំនុំបានទេ ។ នៅក្នុងឋានៈខ្ញុំជាអ្នកនៅខាងក្រៅសម្លឹងមើលមកខាងក្នុងនៅក្នុងខណៈដែលខ្ញុំបានចំណាយពេលនៅក្នុងពេលធ្វើសិក្ខាសាលាអ្នកនិពន្ធនៅក្នុង៤ែ កញ្ញានោះខ្ញុំសប្បាយចិត្តណាស់នូវអ្វី ដែលខ្ញុំបានឃើញ ។ ថ្វីត្បិតតែការអភិវឌ្ឍន៍អ្នកនិពន្ធបណ្ណាធិការ និងអ្នកបោះពុម្ពនៅមានកំរិតក៏ពិតមែននិមិត្តរបស់អស់អ្នកដែលបានមកចូលរួម នៅក្នុងសិក្ខាសាលាបានលេចធ្លោឡើងនៅគ្រប់វិស័យទាំងអស់គឺជាការចាប់ផ្តើមមួយដ៏ល្អពិសេសក្រៃលែង ។

ដូច្នេះក្នុងនាមខ្ញុំជាអ្នកនៅខាងក្រៅ ខ្ញុំអធិស្ឋានសូមឲ្យក្រុមជំនុំ ខ្មែរ និង អ្នកដឹកនាំរបស់ក្រុមជំនុំឲ្យគេឃើញនូវអ្វីដែលខ្ញុំជឿត្រូវការចាំបាច់បំផុតនោះគឺ ៖

១. ក្រុមជំនុំត្រូវលុតជង្គង់ចុះហើយអធិស្ឋានដើម្បីឲ្យមានការចូលរួម និងមានស្មារតីបន្ទាបខ្លួនដូចជាព្រះគ្រីស្ទ ដើម្បីឲ្យគេឃើញអ្នករាល់គ្នាតាមរយៈ សក្ខានុពលខ្លះៗដែលអ្នករាល់គ្នាមាន ។ បទគម្ពីរបានលើកទឹកចិត្តឲ្យយើងមាន ស្មារតីជាអ្នកដែលអាចបង្រៀនបានគឺ "កុំធ្វើអ្វីដោយចង់ប្រកួតប្រជែង ឬ ដោយ អួតបំប៉ោងឡើយ ផ្ទុយទៅវិញត្រូវដាក់ខ្លួនហើយចាត់ទុកអ្នកឯទៀតៗថា ប្រសើរ ជាងខ្លួន ។ ក្នុងចំណោមបងប្អូនម្នាក់ៗ កុំគិតពីប្រយោជន៍ផ្ទាល់ខ្លួនឡើយគឺត្រូវ គិតដល់ប្រយោជន៍អ្នកដទៃវិញ" [២] ។

២. ការប្តេជ្ញាផ្តល់ពេលវេលាពីសំណាក់អ្នកមានកិត្តិវិជ្ជាខ្ពង់ខ្ពស់ និង អ្នកមានភាពចាស់ទុំខាងវិញ្ញាណនៅក្នុងក្រុមជំនុំខ្មែរ ដើម្បីឲ្យគេយល់នូវ ភាពផ្សេងគ្នារវាងអ្វីជា " ការបន្ទាន់ " និងអ្វីជា " ការចាំបាច់សំរាប់អនាគត "។ គឺជាពន្ធកិច្ចមួយដែលនៅក្នុងក្រុមជំនុំមានរួចទៅហើយ នោះ គឺជាព្រះពរ និង ការថែបំប៉ននូវសេចក្តីពិតដែលបានហូរចេញអាសនានៃការអធិប្បាយ សូមឲ្យ ក្លាយទៅជាខិត្តប័ណ្ណដើម្បីឲ្យអ្នកដទៃទទួលបានព្រះពរទាំងនោះផង ឥឡូវនេះ និងប៉ុន្មានឆ្នាំខាងមុខ ។

៣. ការខំប្រឹងប្រែងផ្តោតអារម្មណ៍លើការស្តារឡើងវិញនូវភាសា ពី បុរាណគឺភាសាខ្មែរ និង ភាសាដទៃផ្សេងទៀត ដើម្បីប្រើជាប្រពន្ធ័អប់រំដល់ សាលាសាធារណៈ និង សាលាឯកជនព្រមទាំងសាលាគ្រីស្ទបរិស័ទផង ។ នៅព្រះគម្ពីរជាភាសាអង់គ្លេស ១៦១១ បែបដែលគេទទួលស្គាល់ស្របច្បាប់ នោះ មានភាពច្រើនញច្រង៉ាងក្នុងភាសារបស់ព្រះគម្ពីរនោះហាក់ដូចជាមាន នៅសព្វថ្ងៃនេះគម្ពីរជាភាសាអង់គ្លេសទាំងនោះបានផ្តល់ឲ្យមានការប្រើប្រាស់ជា

---

[២] *ភីលីព ២:៣-៤*

មាត្រដ្ឋានរាប់សតវត្សរ៍មកហើយ ។ សំណោររបស់វៀលលាម សេកខេស្ពារ ក៏បានរួមចំណែកក្នុងការរក្សាភាសាឲ្យមានស្ថេរភាពនៃតួអក្សរសិល្ប៍បែបនោះដែរ ។ ការងារនៅវែងឆ្ងាយខាងមុខទៀត ក្នុងការអភិវឌ្ឍន៍ខិត្តប័ណ្ណផ្នែកត្រីស្តបរិស័ទនោះត្រូវការគំរូនៃភាសាដែលច្បាស់លាស់ដើម្បីឲ្យអាចឈររឹងមាំបាននៅក្នុងពេលទទួលរងនូវការល្បងល ។

ប្រជាជាតិជាច្រើននៅជុំវិញសាកលលោកគឺកំពុងនៅលើគែមនៃការរំលំរលាយដែលបណ្តាលមកពីបញ្ហាផ្ទៃក្នុង ដូចជាប្រទេសកម្ពុជាបានទទួលរងក្នុងរយៈពេលប៉ុន្មានឆ្នាំ កាលពីអតីតកាលនោះអាចផ្តល់ឲ្យនូវគំរូដ៏មានតម្លៃដែលក្រុមជំនុំអាចស្តារឡើងនូវស្ថានភាពដុនដាបនោះ គឺអាចផ្តល់ជាជំនួយក្នុងការអភិវឌ្ឍន៍ ឡើងវិញរបស់ប្រជាជាតិដែលកំពុងរើបៗ ឡើងវិញពីស្ថានភាពដុនដាបពីអតីតកាល ។

ចំពោះយើងដែលជាអ្នកនៅខាងក្រៅគឺសង្ឃឹមអធិស្ឋាន និង មិនមានបំណងគ្រប់គ្រង ឬ ប្រើល្បិចជិះជាន់នោះឡើយតែគឺយើងត្រូវជួយស្ថាបនាក្នុងគ្រប់មធ្យោបាយដែលយើងអាចជួយបាន ។ យើងបានដឹងពីគ្រោះថ្នាក់ដ៏សំខាន់ដែលបានចង្អុលបង្ហាញនៅក្នុងអត្ថបទរបស់លោក អ៊ួន សិលា នៅក្នុងសំណុំទឹកឃ្មុំដែលបានបោះពុម្ពផ្សាយនៅក្នុងខែកក្កដា [៣]។ វាជារឿងមិនត្រឹមត្រូវឡើយចំពោះនរណាម្នាក់ដែលនៅខាងក្រៅព្យាយាមនាំយកទំនៀមទំលាប់ដែលចម្លែក និង នាំឲ្យបែកបាក់ ឬ គំនិតផ្នែកទេវសាស្រ្តចូលមកក្នុងក្រុមជំនុំខ្មែរជាពិសេសនៅចំពេលដែលខ្មែរកំពុងខំស្តារឡើងវិញពីជម្ងឺសង្គមធ្ងន់ធ្ងរនេះ ។

ជាពិសេសជាងនេះទៅទៀតខ្ញុំបានទទួលនូវការលើកទឹកចិត្តនិងសប្បាយរីករាយយ៉ាងក្រៃលែងចំពោះដំណើរមកទស្សនៈកិច្ចរយៈពេលខ្លីរបស់

---

*[៣] អ៊ួន សិលា " មាន់ជល់មិនស្គាល់ជៅសន្ដាន " សំណុំទឹកឃ្មុំ ៤/២ (កក្កដា ២០០៣) ១០:១៥*

ខ្ញុំ ។ ខ្ញុំមិនបានជួបមនុស្សច្រើនទេក្នុងរយៈពេលខ្លីនៃការស្នាក់នៅក្នុងទីក្រុងភ្នំពេញរបស់ខ្ញុំ ប៉ុន្តែអ្នកដឹកនាំ ១៥ នាក់ដែលខ្ញុំបានជួបនៅពេលសិក្ខាសាលាគឺមានន័យច្រើនណាស់នៅក្នុងគំនិតនិងក្នុងការអធិស្ឋានរបស់ខ្ញុំនៅថ្ងៃអនាគតដែលខ្ញុំមានឱកាសដើម្បីចែកចាយនូវអ្វីដែលខ្ញុំបានរៀននៅទីនោះ ។

# រឿងប្រៀបប្រដូចទាំងបី

## (១) ទឹកចិត្តឪពុក



*អ្នកស្រី ទ្រឿង លាភរំលឹក*

នាល្ងាចថ្ងៃអាទិត្យមួយដែលមានភ្លៀងរលឹមស្រិចៗ កាលពីខែមុននេះ។ ក្រោយពីបរិភោគបាយល្ងាចរួចហើយ ខ្ញុំបានទៅអង្គុយនៅមុខទូរទស្សន៍កំពុងតាមដានមើលព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ ។ កូនៗខ្ញុំក៏មកអង្គុយជិតជុំក្បែរខ្ញុំដែរ ពេលនោះទូរទស្សន៍កំពុងបញ្ចាំងអំពីការឃាត់ខ្លួនយុវជនមួយចំនួនដែលប្រើថ្នាំញៀនគួរឲ្យរន្ធត់ដែលឆ្លងមកពីប្រទេសជិតខាងយើងនេះ។ ស្រាប់តែកូនស្រីខ្ញុំម្នាក់ពោលទៅកាន់បងប្រុសវាថា ៖ " អ៊ូ! បងខានិយាយអីចឹងមិត្តភក្តិបងឯងដែលញៀនថ្នាំនុះ!ម៉េចទៅហើយ?"។ បងប្រុសឆ្លើយថា ៖" ប្ញទ្ធីនុះឬ ? គេជាហើយ! "។

កាលពួកូនៗរបស់ខ្ញុំដំណាលពីរឿងមិត្តភក្តិដូច្នេះ ខ្ញុំក៏សួរទៅកូនប្រុសច្បងជាថ្មីម្តងទៀតថា ៖ " ខា ! នរណាទៅឈ្មោះបុទ្ធីនោះ? តើគេកើតអី? " ។ កូនប្រុសច្បងខ្ញុំក៏បានរៀបរាប់រឿងរ៉ាវហួរហែរថា៖ "ម៉ាក់ភ្លេច ហើយឬ ? បុទ្ធីនេះជាមិត្តខ្ញុំកាលនៅរៀនវិទ្យាល័យបាក់ទូកជាមួយគ្នានោះអី គេក៏ធ្លាប់មកលេងផ្ទះយើងដែរ ។ បុទ្ធីនេះជាកូនរបស់លោកពូប្រាក់ សម្បត្តិ មានវីឡាយ៉ាងធំនៅឯទួលគោក ។ ប៉ារបស់គេមានណាស់មានរថយន្តពីរបីគ្រឿងឯណោះ។ ពេលប្រឡងមធ្យមសិក្សាជាប់ហើយគេបានបន្តការសិក្សានៅក្នុងវិទ្យាស្ថានជាតិគ្រប់គ្រងខាងផ្នែកគ្រប់គ្រងនៅជិតវត្តភ្នំ ។ កាលពីឆ្នាំទៅនេះគេប្រឡងបានជាប់បរិញ្ញាប័ត្រហើយ ។ កូនស្រីខ្ញុំម្នាក់ទៀតសួរថា៖ " គេរៀនចប់គេទៅធ្វើអីបានជាធ្លាក់ខ្លួនបែបនេះបង? "។
បងប្រុសក៏បន្ត ៖" កូនអ្នកមានងាយស្រួលណាស់មិនដូចយើងកូនអ្នកក្រទេ ដែលបោះដៃទៅចេះតែផុត ។ ក្រោយពីទទួលបានបរិញ្ញាប័ត្រ ហើយបុទ្ធីបានសុំដើមទុនពីឪពុករបស់ខ្លួនទៅបើកក្រុមហ៊ុនទេសចរណ៍មួយនៅខេត្តសៀមរាប ។ ឪពុកស្រឡាញ់កូន កូនសុំអ្វីក៏យល់ព្រម ហើយបន្សល់ទុនយ៉ាងច្រើនឲ្យកូនទៅរកស៊ី។ ដំបូងបុទ្ធីខិតខំព្យាយាមធ្វើការងារជាម្ចាស់ក្រុមហ៊ុនដ៏ល្អ។ ប៉ុន្តែក្រោយមកបុទ្ធីបានស្គាល់មិត្តភក្តិជាច្រើន ដែលអូសទាញខ្លួនឲ្យធ្លាក់ក្នុងការសប្បាយភ្លើតភ្លើនឆ្លងពីវប្បធម៌ អាក្រក់នៃប្រទេសជិតខាងចេះដើរលេងស៊ីផឹកស្រីស្រា ភ្លេចអស់ពីការ រកស៊ី។ ទីបំផុតក៏ធ្លាក់ខ្លួនជាអ្នកញៀនថ្នាំទៀត។ ពេលនោះបុទ្ធីបានបាត់បង់ភាពជាយុវជនថ្លៃថ្នូរ ខ្វះចំណេះដឹងទៅវិញ។ ក្រោយមកក្រុមហ៊ុនទេសចរណ៍នោះក៏ត្រូវបិទទ្វារដែរ ។ បុទ្ធីគ្មានសល់អ្វីសោះឡើយ ។ បន្ទាប់មកបុទ្ធីដឹងខ្លួនថា ខ្លួនបានបំផ្លាញនូវអ្វីៗគ្រប់បែបយ៉ាងដែលឪពុកម្តាយផ្តល់ឲ្យ ។ ថែមទាំងធ្លាក់ខ្លួនជាអ្នកញៀនថ្នាំទៀត ដែលសង្គមស្អប់ខ្ពើម មិនសមជាបញ្ញវន្តឡើយ ។ ក្រោយពីពិចារណាហើយ បុទ្ធីសំរេចចិត្តវិលត្រលប់មកភ្នំពេញសុំទោសឪពុកម្តាយរបស់ខ្លួនវិញ ទោះបីជាខ្លួន

ភ័យខ្លាចនឹងឪពុកធ្វើទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរចំពោះខ្លួនក៏ដោយ ។ ពេលមកដល់ផ្ទះឫទ្ធីភ័យណាស់ ស្ទើរតែមិនហ៊ានចូល ។ ប៉ុន្តែកាលឪពុកឃើញកូនដែលស្គមស្គាំងដូច្នេះ ឪពុកអាណិតកូនជាខ្លាំង ។ ចំណែកឫទ្ធីកាលឃើញឪពុកក៏លុតជង្គង់ចុះក្រាបសំពះសុំទោសឪពុក ។ ប៉ុន្តែឪពុកបានស្ទុះទៅលើកកូនឡើងរួចស្រែកប្រាប់បងប្អូនរបស់គេឲ្យមកដើម្បីទទួលអបអរសាទរបងរបស់ខ្លួនដែលត្រលប់មកវិញ។ បន្ទាប់មកគាត់បានទៅរកគ្រូពេទ្យដ៏ពូកែឲ្យជួយព្យាបាលកូនប្រុសរបស់គាត់ឲ្យបានជាដាច់ពីការញៀនថ្នាំនេះ។ នៅក្នុងឆ្នាំនេះប៉ារបស់ ឫទ្ធីបានឲ្យគេទៅរៀនបន្តយកថ្នាក់បណ្ឌិតថែមទៀត ។ កូនប្រុសពៅជិតទង់ខ្ញុំក៏លាន់មាត់ថា៖ "ប៉ាបងឫទ្ធីចិត្តល្អមែន ! គាត់ស្រឡាញ់កូនណាស់ !"។

ពាក្យទាំងប៉ុន្មានម៉ាត់ចុងក្រោយរបស់កូនពៅខ្ញុំ ធ្វើឲ្យខ្ញុំនឹកដល់រឿង " កូនពៅវង្វេងដែលព្រះយេស៊ូលើកជាប្រស្នាបំភ្លឺពួកគណៈផារីស៊ី។ ស្តីអំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះបិតាចំពោះយើងដែលជាកូនស្ងួនភ្ងាដែលតែងតែប្រព្រឹត្តអំពើខុសឆ្គងទាស់នឹងព្រះអង្គជានិច្ចកាល។ ប៉ុន្តែព្រះបិតាតែងអត់ទោសបាបឲ្យយើង នៅពេលយើងភ្ញាក់រលឹកវិលមករកព្រះអង្គវិញ ។ ព្រះបិតាទ្រង់ពុំដែលប្រកាន់យើងនោះឡើយ។

រឿងរ៉ាវទាំងនេះក៏ឆ្លុះបញ្ចាំងអំពីវិបត្តិក្នុងសង្គមបច្ចុប្បន្នដែរ។ អំពីការយកចិត្តទុកដាក់អប់រំយុវជនកុំឲ្យលង់ក្នុងអំពើឧបាយមុខ ។ កុំឲ្យភ្លើតភ្លើននឹងឥទ្ធិពលនៃវប្បធម៌បរទេសដែលហូរមកពីប្រទេសជិតខាងដែលនាំឲ្យធ្លាក់ខ្លួនក្នុងភាពវិនាសវិន្តរាយ។ យើងដឹងច្បាស់ហើយថា យុវជនជាទំពាំងឫស្សី ។ បើយុវជនមិនស្គាល់តំលៃនៃជីវិតរបស់ខ្លួន ដែលជាបុត្ររបស់ព្រះជាម្ចាស់ទៅប្រព្រឹត្តអំពើអសីលធម៌ដែលសង្គមស្អប់ខ្ពើម នោះយុវជននឹងក្លាយទៅជាអំបិលដែលគ្មានជាតិប្រៃឡើយ ។ ដូច្នេះយុវជនត្រូវចេះរិះគិតពិចារណាក្នុងការសេពគប់មិត្តភក្តិកុំតាមការអូសទាញ កុំភ្លើតភ្លើននឹង

ទ្រព្យសម្បត្តិត្រូវចេះរស់នៅឲ្យបានថ្លៃថ្នូរជាពលរដ្ឋដ៏ល្អរួមគ្នាកសាងសង្គម
មួយយ៉ាងស្អាតស្អំប្រកបដោយសេចក្តីសុខសាន្ត។

## (២) អ្នកបំរើដ៏ស្មោះត្រង់



*លោក ឡុង សម្បត្តិ*

ជនជាតិអាមេរិកពីរនាក់ឈ្មោះដេល និងរិកកំពុងធ្វើដំណើរ កំសាន្ត នៅក្នុងទីរួមខេត្តសៀមរាប ។ ពេលកំពុងធ្វើដំណើរថ្មើរជើង ដេលក៏ស្ទាប ហោប៉ៅរបស់ខ្លួន ហើយក៏ភ្ញាក់ខ្លួនយ៉ាងដោយដឹងថាកាបូបលុយដែលមាន ទឹកប្រាក់ជាងមួយពាន់ដុល្លាអាមេរិចព្រមទាំងលិខិតឆ្លងដែនរបស់ខ្លួនបាន ជ្រុះបាត់ដោយមិនដឹងខ្លួន ។ ដេល ហើយនឹង រិក ចាប់ផ្តើមភ័យស្លន់ស្លោរទាំង ខំប្រឹងដើររកវត្ថុទាំងនោះនៅគ្រប់ទិសទីនៅ ក្រោម កំដៅថ្ងៃ ត្រង់ក្នុងឆ្នាំ ១៩៩៩។

ពេលគាត់កំពុងស្វែងរកស្រាប់តែមានជនជាតិជប៉ុនម្នាក់មកស្ទាក់ សួរគាត់ថា៖ "តើលោកឈ្មោះអ្វី? "ដោយគាត់កំពុងក្តៅក្រហាយបាត់របស់ ដ៏មានតំលៃដូច្នេះ។ គាត់ក៏តបទៅវិញដោយសភាពក្រៀវក្រោធថា៖ តើអ្នក ឈ្មោះអ្វី ? គាត់ក៏បន្តដំណើរទៅមុខទៀតឥតឈប់ឈរ។

មួយស្របក់ក្រោយមក ដេលឃើញជនជាតិជប៉ុនដដែលនោះមកស្ទាក់ផ្លូវគាត់ម្ដងទៀតហើយសួរថា៖ " តើលោកឈ្មោះអ្វី ? "ដេលក៏ឆ្លើយតបទៅវិញថា៖ " តើលោកឈ្មោះអ្វី? " ។ ថ្ងៃរសៀលបន្តិចស្រាប់តែឃើញជប៉ុននោះមកសួរជាថ្មីម្ដងទៀតតាមរបៀបដដែលថា៖" តើលោកឈ្មោះអ្វី ?" ដោយសភាពងឿងឆ្ងល់ ដេលក៏ឆ្លើយប្រាប់ទៅជប៉ុននោះតាមរបៀបសមគួរថា៖" ខ្ញុំឈ្មោះដេល" ។

ជប៉ុននោះក៏សួរបន្ត ថា" តើត្រកូលរបស់លោកជាអ្វី ?"

គាត់ក៏ឆ្លើយទៅថា៖"ឈ្មោះចូន្ស"

ចុះលោកមានការអ្វី ?" ជប៉ុននោះបានរូបថតមួយសន្លឹកហើយសួរថា ៖"តើនេះ ជារូបថតរបស់លោកមែនទេ? "

ដោយក្ដីរំភើបរីករាយ ដេល បានយករូបថតនោះមកកាន់ហើយឆ្លើយថា៖ "នេះជារូបថតរបស់ខ្ញុំ "។

ជនជាតិជប៉ុននោះក៏បានប្រគល់កាបូបលុយដែលមានទឹកប្រាក់ជាងមួយពាន់ដុល្លា ព្រមទាំងលិខិតឆ្លងដែនទាំងអស់មកដេលវិញ ។ ដេល មានចិត្តរំភើបរីករាយលាយឡំនឹងភាពសោកស្ដាយដែលគាត់បានប្រើពាក្យត្រគោះបោះបោកដាក់បុរសនោះ ។ ដេល ក៏សុំអភ័យទោសជាខ្លាំងរួមទាំងទឹកចិត្តដឹងគុណាឥតឧបមាផងដែរ។

ជនជាតិជប៉ុននោះជាមនុស្សស្មោះត្រង់ ។ ចុះនៅក្នុងសង្គមគ្រីស្ទបរិស័ទវិញ តើមានអ្នកដឹកនាំប៉ុន្មាននាក់ដែលមានចិត្តស្មោះត្រង់ប្ដូរផ្ដាច់រក្សាភាពស្អាតស្អំរបស់ខ្លួនជាអ្នកគោរពកោតខ្លាចព្រះជាម្ចាស់ ?

ព្រះយេស៊ូមានព្រះបន្ទូលថា ៖" បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ នោះអ្នកមុខជាប្រតិបត្តិតាមពាក្យរបស់ខ្ញុំ ... អ្នករាល់គ្នាត្រូវលីឈើឆ្កាងរបស់ខ្លួនជារៀងរាល់ថ្ងៃ ... ។ ព្រះជាម្ចាស់មិនបានបង្កើតមនុស្សមកដើម្បីឲ្យគេធ្វើអ្វីៗតាមចិត្តរបស់គេឡើយ ។ ផ្ទុយទៅវិញ ព្រះអង្គបង្កើតមនុស្សដើម្បីឲ្យគោរព

ថ្វាយបង្គំព្រះអង្គតែមួយគត់ ។ ការថ្វាយបង្គំមិនមែនត្រឹមតែនៅក្នុងព្រះវិហារមួយអាទិត្យម្តងឡើយ ។ តែការថ្វាយបង្គំគឺជាសកម្មភាពរាល់វិនាទីដែលតម្កើងដល់ព្រះនាមព្រះអង្គ ។ បើលោកអ្នកមិនធ្វើល្អជាមួយមនុស្សតើលោកអ្នកមានឈ្មោះជាតម្កើងព្រះអង្គដោយរបៀបណា?

យើងមិនត្រូវភ្លេចនូវអំពើល្អដែលមនុស្សបានធ្វើ។ ប៉ុន្តែយើងក៏ត្រូវចងចាំដែរថា យើងមិនត្រូវប្រព្រឹត្តល្អដើម្បីឲ្យបានការសង្គ្រោះទេតែយើងបានទទួលការសង្គ្រោះដើម្បីប្រព្រឹត្តល្អហើយយើងត្រូវតែប្រព្រឹត្តល្អ ដោយក្តីរីករាយចេញពីដួងចិត្ត។ ជប៉ុននោះបានធ្វើល្អដោយក្តីរីករាយអស់ពីចិត្តមែន ។ ការខាតបង់មិនមែនជាគោលបំណងរបស់មនុស្សទេ ប៉ុន្តែភាពស្អាតស្អំ និង ការប្រព្រឹត្តិល្អគឺជាទំលាប់ក្នុងជីវិតរស់នៅរបស់ជនជាតិជប៉ុននោះ។

ការដែលប្រព្រឹត្តិល្អមិនមែនកើតឡើងដោយឯកឯងទេ ។ ព្រោះមនុស្សកើតមកក្នុងពិភពលោកដែលមានបាបហើយ និស្ស័យបាបតម្រូវឲ្យមនុស្សមានទំនោរទៅរកការអាក្រក់ ។ ការប្រព្រឹត្តិល្អអាចកើតឡើងបាន លុះត្រាមនុស្សមានកំលាំងជំរុញ ម្យ៉ាងដែលនៅខាងក្នុងអ្នកនោះដែលជាសេចក្តីស្រឡាញ់ ។ ព្រះបុត្រាយាងមកក្នុងពិភពលោកនេះ មិនមែនដោយសារបុគ្គលណាម្នាក់បានបង្ខិតបង្ខំព្រះអង្គឡើយ ។ ប៉ុន្តែទ្រង់ស្ម័គ្រព្រះទ័យយាងមកក្នុងលោកនេះដោយសារក្តីស្រឡាញ់ដែលព្រះអង្គមានចំពោះមនុស្ស ។ សេចក្តីស្រឡាញ់ធ្វើឲ្យព្រះអង្គហ៊ានបូជាព្រះជន្មទ្រង់ដើម្បីប្រយោជន៍របស់មនុស្ស។

ការប្រព្រឹត្តិល្អគឺជាការតម្កើងដល់ព្រះនាមទ្រង់ហើយក្តីស្រឡាញ់ដែលយើងមានមិនគ្រប់គ្រាន់ដែរ ។ ភាពស្មោះត្រង់តម្រូវឲ្យមនុស្សមានការប្តូរផ្តាច់ដែលជាចំណុចចាំបាច់ ។ ជនជាតិជប៉ុននោះសុខចិត្តឲ្យគេត្មេះដៀលមាក់ងាយគ្រប់យ៉ាង ។ ទាល់តែគាត់អាចរកឃើញម្ចាស់លិខិតឆ្លងដែន និង លុយគ្រប់ចំនួនដើម្បី ប្រគល់ឲ្យម្ចាស់ដើមវិញ ។ ដើម្បីឲ្យបេសសកម្ម បានសម្រេចព្រះយេស៊ូហ៊ានប្រឈមនឹង ពួកផារិ និង បណ្ឌិតខាងវិន័យជាច្រើនមានពេលខ្លះ

ត្រូវគេតិះដៀលរហូតដល់គេឆ្កាងទ្រង់ទៀតផង ។ ការប្តូរផ្តាច់គឺជាជំហដ៏រឹងមាំរបស់អ្នកដឹកនាំ ហើយក៏ជាជោគជ័យគ្រប់កិច្ចការ។

ជាទីបញ្ចប់ ព្រះយេស៊ូកំពុងផ្តល់ឱកាសឲ្យលោកអ្នកវិលមករកព្រះអង្គវិញដើម្បីស្រូបយកកំលាំងពីព្រះអង្គ និង ដើម្បីកែច្នៃជីវិតលោកអ្នកឲ្យទៅជាត្បូងមួយគ្រាប់ដែលភ្លឺចិញ្ចាចសំរាប់លោកីយ៍កំពុងបាត់បង់ ។ ទោះលោកអ្នកស្ថិតនៅក្នុងសភាពបែបណាក៏ដោយព្រះអង្គនៅតែត្រូវការលោកអ្នកជានិច្ច។

លោកអ្នកគឺជាគំរូសំរាប់មនុស្សដទៃដោយការប្រព្រឹត្តិល្អ និង ការប្តូរផ្តាច់ចំពោះកិច្ចការដែលលោកអ្នកធ្វើ។ ព្រះអង្គទន្ទឹងរង់ចាំពេលវេលាមួយដែលត្រូវជួបលោកអ្នកពេលនោះព្រះអង្គមានបន្ទូលថា ៖" ល្អហើយ ! អ្នកបំរើដ៏ប្រសើរមានចិត្តស្មោះត្រង់អើយ ... ចូរអ្នកចូលមកសប្បាយរួមជាមួយខ្ញុំចុះ" ( ម៉ាថាយ ២៥:២១-២២)។

# (៣) ឪពុកខ្ញុំ និងក្តីស្រឡាញ់



*លោក សៅខុន សិរីវឌ្ឍន៍*

បើនិយាយពីកម្ពុជានោះនឹងធ្វើឲ្យគេនឹកឃើញទៅដល់អង្គរវត្តដ៏ល្បីល្បាញដែលទាក់ទាញចង់ឲ្យមនុស្សជាច្រើនគេឃើញឲ្យបានម្តងក្នុងជីវិតរបស់គេ។ ហើយក៏បានធ្វើឲ្យនឹកគិតទៅដល់របប ប៉ុល ពត ដ៏ខ្មៅងងឹតដែលជីវិតប្រជាជនរាប់លាននាក់បានបាត់បង់ ។ លេចឡើងនូវចម្ងល់ជាច្រើនដែលគ្មានចម្លើយណាច្បាស់លាស់សំរាប់ពួកគេនៅឡើយ ។ ខ្លះគាត់ឆ្ងល់ថា តើជីវិតប្រជាជននាពេលនោះយ៉ាងម៉េចដែរ?

ខ្ញុំក៏ជាមនុស្សម្នាក់ដែលស្ថិតក្នុងចំណោមមនុស្សដទៃទៀតដែលបានឆ្លងកាត់របបដ៏អប្រិយនោះដែរ ។ នៅថ្ងៃ ១៧ មេសា ១៩៧៥ ប្រជាជនដែលរស់នៅទីក្រុងគ្រប់គ្រួសារគឺត្រូវបានពួកទាហានអាវខ្មៅបង្ខំឲ្យចាកចេញពីទីក្រុងទៅតំបន់ផ្សេងៗតាមខេត្តនានានៃប្រទេសកម្ពុជា។ នៅពេលនោះគ្រួសារខ្ញុំក៏ទទួលការបង្ខំឲ្យចាកចេញទៅក្រៅទីក្រុងដែរ ។ នៅតាមផ្លូវមានមនុស្សកកកុញ ។ ឪពុកខ្ញុំ និងគ្រួសារខ្ញុំបានធ្វើដំណើរមិន ដឹងឆ្ពោះទៅទីណា

ឲ្យច្បាស់លាស់ទេ ។ គឺចេះតែដើរតាមគេទៅដោយសារនៅពេលនោះខ្ញុំទើបតែមានអាយុ ៦ ឆ្នាំប៉ុណ្ណោះ។ ឪពុកក៏និយាយថា "ម៉ោរ ! ប៉ាពរ !"។ ឪពុកក៏លើករូបខ្ញុំពរក្រោយមកក៏អៀវិញ ។ នៅលើខ្នងរបស់គាត់ធ្វើឲ្យខ្ញុំមានចិត្តរីករាយនៅលើខ្នងរបស់គាត់ធ្វើឲ្យខ្ញុំមានចិត្តរីករាយ កក់ក្តៅដែលសេចក្តីសុខនោះរកពាក្យអ្វីមករៀបរាប់ឲ្យស្មើរពុំបាន ។ ជារឿយៗ នៅពេលដើរតាមផ្លូវខ្ញុំតែងសួរឪពុកថា "ប៉ា ! ប៉ា ! ធ្ងន់ទេ ?" គាត់ឆ្លើយ "អត់ទេ "។ ខ្ញុំបានមានសំណួរទៅកាន់គាត់ជាច្រើននូវពេលខ្ញុំបានឃើញអ្វីដែលមិនស្គាល់និងមិនយល់ ។ ជាញឹកញាប់ពួកយើងបានសើចជាមួយគ្នាការនេះគួរ ឲ្យសប្បាយមែនទែន!

ត្រង់នេះ ! បានធ្វើឲ្យយើងមើលឃើញក្តីស្រឡាញ់របស់ឪពុកចំពោះកូន ។ រីឯចំពោះព្រះជាម្ចាស់គឺមិនខុសគ្នាទេ ។ ព្រះអង្គស្រឡាញ់យើងជាកូនការពារយើងលើកយើងពរចេញផុតពីការលំបាកវេទនាដែលបណ្តាលមកពីអំពើបាប ។ ក្តីស្រឡាញ់របស់ទ្រង់គឺមិនដែលត្អូញត្អែរទេ ទ្រង់នៅតែការពារ និង ថែទាំដល់យើងគ្រប់ទាំងកាលៈទេសៈព្រះអង្គទ្រង់បានលះបង់គ្រប់យ៉ាងក៏ព្រោះតែទ្រង់ស្រឡាញ់កូនរបស់ព្រះអង្គ ។ ដូចគម្ពីរបានចែងថា " ក្រោយមកនៅវាលរហោស្ថានតាមផ្លូវដែលអ្នករាល់គ្នាធ្វើដំណើររហូតមកដល់កន្លែងនេះអ្នកឃើញស្រាប់ ហើយព្រះជាម្ចាស់ជាព្រះរបស់អ្នកបីអ្នកដូចឪពុកបីកូន" ( ចោទិយកថា ១:៣១ ) ។

- នៅពេលណាដែលកូនជួបបញ្ហាឪពុកតែងការពារកូន
- ការការពារថែរក្សាគឺដោយសារក្តីស្រឡាញ់
- ដោយក្តីស្រឡាញ់ព្រះជាម្ចាស់បានលះបង់គ្រប់បែបយ៉ាង ដើម្បីការពារ និង ឃុំគ្រងយើង។